សេចក្តីប្រកាសព័ត៌មានរួម

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦

មូលបត្របំណុលហេដ្ឋារចនាសម្ព័ន្ធតម្លៃ ៩៩ លានដុល្លារអាមេរិក ដែលជាកំណត់ត្រាថ្មីនៅលើផ្សារមូលបត្រកម្ពុជា បើកផ្លូវដល់កញ្ចប់ហិរញ្ញប្បទានថាមពលពន្លឺព្រះអាទិត្យតម្លៃ ១៥០ លានដុល្លារអាមេរិក

រដ្ឋាភិបាលអូស្ត្រាលី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ផ្សារមូលបត្រកម្ពុជា (ផែក) រដ្ឋាភិបាលលុចសំបួ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) និងក្រុមហ៊ុន ស្នេថេក ជុកឺធើរ នៅថ្ងៃនេះ បានប្រារព្ធពិធីចុះបញ្ជីលក់មូលបត្របំណុលគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលមានតម្លៃ ៩៩ លានដុល្លារអាមេរិក ដែលជាការបោះផ្សាយមូលបត្របំណុលប្រភេទនេះធំជាងគេបំផុតនៅកម្ពុជារហូតមកដល់បច្ចុប្បន្ន។ មូលបត្របំណុលនេះ គឺជាផ្នែកមួយនៃកញ្ចប់ហិរញ្ញប្បទានសរុបដែលមានតម្លៃ ១៥០ លានដុល្លារអាមេរិក។

មូលបត្របំណុលនេះ នឹងផ្តល់ហិរញ្ញប្បទានឡើងវិញដល់ការវិនិយោគលើកសិដ្ឋានថាមពលពន្លឺព្រះអាទិត្យកម្លាំង ៣៥០ មេហ្គាវ៉ាត់ (MW) ដែលជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ទីផ្សារមូលបត្ររបស់កម្ពុជា និងកិច្ចខិតខំប្រឹងប្រែងក្នុងការកៀរគរហិរញ្ញប្បទានឯកជនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ស្ថិតនៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ រោងចក្រថាមពលនេះមានសមត្ថភាពអាចផ្គត់ផ្គង់អគ្គិសនីដល់លំនៅឋានប្រជាពលរដ្ឋកម្ពុជាប្រមាណជាជាង ២០០ ០០០ ខ្នងផ្ទះ។ គម្រោងនេះជាផ្នែកមួយនៃមជ្ឈមណ្ឌលថាមពល ដើរដោយពន្លឺព្រះអាទិត្យកម្លាំង ៩៣០ មេហ្គាវ៉ាត់ ដែលជាគម្រោងអភិវឌ្ឍន៍ថាមពលពន្លឺព្រះអាទិត្យធំជាងគេបំផុតនៅតំបន់អាស៊ីអាគ្នេយ៍។

ការបោះផ្សាយមូលបត្របំណុលនេះ ជាលទ្ធផលនៃការងារភាពជាដៃគូរបស់ប្រទេសអូស្ត្រាលីជាមួយ ន.ម.ក. ដើម្បីពង្រឹងទីផ្សារមូលបត្ររបស់កម្ពុជា។ តាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) អូស្ត្រាលីបានផ្តល់ជំនួយបច្ចេកទេសដល់ ន.ម.ក. ក្នុងការរៀបចំប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលហេដ្ឋារចនាសម្ព័ន្ធ។ ប្រកាសនេះត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងខែកក្កដា ឆ្នាំ២០២៥ ដោយបានបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនសាធារណៈ និង ឯកជនអាចកៀរគរហិរញ្ញប្បទានរយៈពេលវែងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

អូស្ត្រាលីបន្តធ្វើការជាមួយ ន.ម.ក. និងវិស័យឯកជន ដើម្បីអនុវត្តក្របខ័ណ្ឌនេះ តាមរយៈការគាំទ្រមួយផ្នែក នៃការចំណាយលើការបោះផ្សាយមូលបត្របំណុលសម្រាប់ ក្រុមហ៊ុនត្រួសត្រាយផ្លូវដំបូង ដូចជាក្រុមហ៊ុន ស្នេថេក ជាដើម។ ការធ្វើបែបនេះ ជួយកាត់បន្ថយឧបសគ្គក្នុងការចូលរួមទីផ្សារមូលបត្រ និងលើកទឹកចិត្តឱ្យមានការវិនិយោគបន្ថែមទៀត។

ការបោះផ្សាយមូលបត្របំណុលនេះ ក៏បានផ្អែកទៅលើកម្មវិធីជំរុញការបោះផ្សាយសញ្ញាបណ្ណចីរភាពនៅកម្ពុជា (CSBA) ដែលទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីមូលនិធិបរធនបាលកិច្ចសកលសម្រាប់ឧបករណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ប្រទេសលុចសំបួរ ក្នុងរូបភាពជាជំនួយបច្ចេកទេសតាមរយៈវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI)។ ការចុះបញ្ជីនេះពង្រីកការប្រើប្រាស់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពសម្រាប់ថាមពលពន្លឺព្រះអាទិត្យខ្នាតធំនៅកម្ពុជា និងគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់វិស័យឯកជនកម្ពុជាក្នុងការគាំទ្រដល់ការផ្លាស់ប្តូរទៅរកថាមពលបៃតង។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជា បានមានប្រសាសន៍ថា "ក្នុងវិស័យថាមពល រាជរដ្ឋាភិបាល បានកំណត់គោលដៅបង្កើនចំណែកថាមពលកកើតឡើងវិញ ក្នុងការផលិតអគ្គិសនីជាតិ ដើម្បីកាត់បន្ថយការពឹងផ្អែកលើឥន្ធនៈហ្វូស៊ីល និង ការនាំចូលថាមពល ព្រមទាំងធានាសន្តិសុខថាមពល ។ ក្នុងន័យនេះ គម្រោងថាមពលព្រះអាទិត្យខ្នាតធំ បានក្លាយជាផ្នែកមួយដ៏សំខាន់ នៃផែនការអភិវឌ្ឍថាមពលរបស់ប្រទេស ដោយកម្ពុជាមានសក្តានុពលខ្ពស់ ពីកាំរស្មីព្រះអាទិត្យពេញមួយឆ្នាំ ។ ហើយការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធបៃតង របស់ក្រុមហ៊ុន ស្នេថេក ជុកគីធើរ នាពេលនេះមិនត្រឹមតែជាការកៀរគរទុនរបស់ក្រុមហ៊ុនឯកជនប៉ុណ្ណោះទេ ប៉ុន្តែ គឺជាការចូលរួមចំណែកដោយផ្ទាល់ ជាមួយរាជរដ្ឋាភិបាល ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីសេដ្ឋកិច្ចបៃតង តាមរយៈការបង្កើតតម្លៃបន្ថែមខ្ពស់ ការបង្កើតការងារបៃតង និង ការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់មនុស្សជំនាន់ក្រោយ »។

ឯកឧត្តមបណ្ឌិតសភាចារ្យ បានគូសបញ្ជាក់នូវប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញវិស័យមូលបត្រនៅកម្ពុជា ឱ្យកាន់តែមានភាពរីកចម្រើន រឹងមាំ មានតម្លាភាព និង ទទួលបានទំនុកចិត្តខ្ពស់ តាមរយៈយុទ្ធសាស្ត្រស្នូលចំនួន ៥ រួមមាន៖ ១). បន្តពង្រឹងក្របខណ្ឌគតិយុត្ត និង អភិបាលកិច្ចសាជីវកម្ម ឱ្យស្របតាមឧត្តមានុវត្តអន្តរជាតិ, ២). បន្តធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុបៃតង, ៣). បន្តលើកទឹកចិត្តក្រុមហ៊ុនបោះផ្សាយ និង ការពង្រីកមូលដ្ឋានវិនិយោគិន, ៤). បន្តរួមចំណែកធ្វើបរិវត្តកម្មឌីជីថល និង នវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ, និង ៥). បន្តលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ និង ការផ្សព្វផ្សាយជាសាធារណៈ អំពី ការវិនិយោគក្នុងវិស័យមូលបត្រ ដល់សាធារណជន ។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា «ប្រទេសអូស្ត្រាលីមានសេចក្តីសោមនស្សរីករាយដែលបានធ្វើការជាមួយ ន.ម.ក. ក្នុងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់មូលបត្របំណុលហេដ្ឋារចនាសម្ព័ន្ធ និងបានរួមចំណែកដល់ការបោះផ្សាយមូលបត្របំណុលដែលជាកំណត់ត្រាថ្មីនេះ។ យើងសង្ឃឹមថា ការណ៍នេះនឹងលើកទឹកចិត្តដល់អាជីវកម្ម និងវិនិយោគិនកាន់តែច្រើនឱ្យដើរតាមគន្លងនេះ ដើម្បីគាំទ្រដល់ការវិនិយោគបន្ថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធ សម្រាប់កំណើនប្រកបដោយនិរន្តរភាព សន្តិសុខថាមពល និងភាពធន់នៃសេដ្ឋកិច្ចរបស់កម្ពុជា»។

ឯកឧត្តម Xavier Bettel ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស ពាណិជ្ជកម្មបរទេស កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងកិច្ចការមនុស្សធម៌លុចសំបួ បានមានប្រសាសន៍ថា «ក្នុងនាមជាមជ្ឈមណ្ឌលសកលសម្រាប់ឧបករណ៍មូលបត្របំណុលប្រកបដោយចីរភាព លុចសំបួមានសេចក្តីរីករាយដែលឃើញថាកិច្ចសហប្រតិបត្តិការរបស់យើងនៅកម្ពុជាតាមរយៈ GGGI បានផ្សារភ្ជាប់មហិច្ឆតាថាមពលស្អាតរបស់ប្រទេសកម្ពុជា ជាមួយនឹងលទ្ធភាពទទួលបានហិរញ្ញប្បទានប្រកបដោយចីរភាព។ យើងសង្ឃឹមថា ការបោះផ្សាយនេះនឹងផ្តល់ទំនុកចិត្តដល់អាជីវកម្ម និងវិនិយោគិនកាន់តែច្រើន ក្នុងការចូលរួមក្នុងទីផ្សារដែលកំពុងរីកចម្រើននេះ»។

ឯកឧត្តម ស៊ូ សុជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ ន.ម.ក. បានមានប្រសាសន៍ថា «ការអភិវឌ្ឍបៃតង គឺជាកត្តាសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការលើកកម្ពស់គុណភាពបរិស្ថាន និងការពង្រឹងសន្តិសុខថាមពលជាតិ។ ក្នុងន័យនេះ ការចុះបញ្ជីលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងបៃតងរបស់ក្រុមហ៊ុន ស្នេថេក ជុកគីធើរ ឯ.ក គឺជាសមិទ្ធផលដ៏មានសារៈសំខាន់មួយ ដែលរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ តាមរយៈការជំរុញការផលិតថាមពលកកើតឡើងវិញ និងការកាត់បន្ថយការពឹងផ្អែកលើការនាំចូលថាមពលអគ្គិសនី។ ជាមួយគ្នានេះ ទីផ្សារសញ្ញាបណ្ណបៃតងក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរហិរញ្ញប្បទានរយៈពេលវែងសម្រាប់គម្រោងអភិវឌ្ឍន៍បៃតងដោយផ្តល់ជា ជម្រើសហិរញ្ញប្បទានបន្ថែមដល់ក្រុមហ៊ុន និងបង្កើតឱកាសវិនិយោគថ្មីៗសម្រាប់វិនិយោគិន។ ជាពិសេស ទីផ្សារនេះអាចរួមចំណែកជំរុញការវិនិយោគលើវិស័យថាមពលកកើតឡើងវិញ និងវិស័យសំខាន់ៗផ្សេងទៀត ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។"

ឯកឧត្តម ហុង សុហួរ អគ្គនាយកនៃផ្សារមូលបត្រកម្ពុជា បានមានប្រសាសន៍ថា «តាមរយៈសមទិ្ធផលនេះ បង្ហាញថាយើងបាន និងកំពុងបំពេញបេសកម្មដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ក្នុងការជួយគាំទ្រដល់ការកៀរគរទុនរយៈពេលវែងរបស់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍអាជីវកម្ម និងរួមចំណែកផ្តត់ផ្គង់ថាមពលស្អាត ប្រកបដោយចីរភាព ជូនដល់ប្រជាពលរដ្ឋកម្ពុជា និងគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ។ យើងខ្ញុំទទួលរង់ចាំស្វាគមន៍នូវសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកទាំងអស់ ក៏ដូចជាក្រុមហ៊ុនអន្តរជាតិនានាដែលមានសក្តានុពល និងមានគុណវុឌ្ឍិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌចុះបញ្ជី ដើម្បីកៀរគរទុនយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព»។

លោកបណ្ឌិត ហេង សុជាតិ អគ្គនាយកក្រុមហ៊ុន ស្នេថេក ជុកីធើរ បានមានប្រសាសន៍ថា «យើងសូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់ ន.ម.ក. ផមក រដ្ឋាភិបាលអូស្ត្រាលី និងដៃគូពាក់ព័ន្ធដទៃទៀត នៅក្នុងដំណើរឆ្ពោះទៅមុខនេះ។ មូលបត្របំណុលនេះបង្ហាញពីរបៀបដែលហិរញ្ញប្បទានប្រកបដោយនវានុវត្តន៍ អាចបើកផ្លូវដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ ទន្ទឹមនឹងការរួមចំណែកដល់សន្តិសុខថាមពល និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់កម្ពុជា»។

ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣ បានកំណត់តម្រូវការវិនិយោគប្រមាណ ៣៦ ពាន់លានដុល្លារអាមេរិក នៅក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្មតែមួយមុខគត់។ ការកៀរគរហិរញ្ញប្បទានឯកជនតាមរយៈទីផ្សារមូលធនរបស់កម្ពុជា អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធកាន់តែទូលំទូលាយរបស់ប្រទេស។

ទំនាក់ទំនងព័ត៌មាន

ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា៖ Media.Cambodia@dfat.gov.au